មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍
# ម.ស.ម.ក ទទួលបានថវិកាខ្នាតតូចរបស់ វ៉ាយស៊ីង វ៉យស៍ និងសម្ពោធគម្រោងពង្រឹងអំណាចអ្នកសរសេរប្លុកស្ត្រីកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ នេះសម្ពោធគម្រោងថ្មីមួយរបស់ខ្លួន គឺគម្រោងពង្រឹងអំណាចអ្នកសរសេរប្លុកស្ត្រីកម្ពុជា និងប្រកាសជ្រើសរើសបេក្ខជនដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងវគ្គបណ្តុះបណ្តាលរបស់គម្រោងនេះ។ គម្រោងនេះមានគោលបំណងពង្រឹងឲ្យមានការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងឥទ្ធិពលរបស់និស្សិតស្ត្រីនៅសាកលវិទ្យាល័យដែលមកពីគ្រប់ទិសទីនៅកម្ពុជាតាមរយៈការបណ្តុះបណ្តាលឲ្យស្ត្រីទាំងនោះក្លាយជាអ្នកសរសេរប្លុកនៅកម្ពុជា និងក្លាយជាអ្នកកាន់តែសកម្មនៅលើប្រព័ន្ធអ៊ីនធឺណិត។ គម្រោងពង្រឹងអំណាចអ្នកសរសេរប្លុកស្ត្រីកម្ពុជារបស់ ម.ស.ម.ក ត្រូវបានជ្រើសរើសជាអ្នកទទួលថវិកាខ្នាតតូចរបស់វ៉ាយស៊ីង វ៉យស៍ ដែលជាគម្រោងមួយរបស់ក្លូបិល វ៉យស៍ អនឡាញ ។

ក្រុមគោលដៅរបស់គម្រោងគឺនិស្សិតស្ត្រីនៃសាកលវិទ្យាល័យនៅប្រទេសកម្ពុជា ដែលបានកំពុងសិក្សានៅក្នុងទីក្រុងភ្នំពេញ និងអ្នកដែលមានចំណាប់អារម្មណ៍ក្នុងការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្តូរសង្គម។ អ្នកចូលរួមនឹងទទួលការបណ្តុះបណ្តាលចំនួន ៥ វគ្គផ្សេងៗគ្នាពាក់ព័ន្ធនឹងការសរសេរប្លុក ដែលរួមមាន ការបង្កើតប្លុកដែលគួរឲ្យចាប់អារម្មណ៍ គន្លឹះក្នុងការសរសេរ យុទ្ធសាស្ត្រប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ក៏ដូចជា ការបង្ហាត់បង្ហាញផ្ទាល់ពី ម.ស.ម.ក ដើម្បីធានាឲ្យស្ត្រីទាំងនោះពិតជាមានជំនាញសំខាន់ៗក្នុងការក្លាយខ្លួនជាអ្នកសរសេរប្លុកដ៏ជោគជ័យ។ លើសពីនេះទៅទៀត សិក្ខាកាមនឹងត្រូវអញ្ជើញឲ្យដើម្បីចូលរួមក្នុងការប្រកួតប្រជែងសរសេរប្លុក និងមានឱកាសដើម្បីបង្កើតបណ្តាញ និងចូលរួមក្នុងសង្គមជាមួយនឹងអ្នកសរសេរប្លុកផ្សេងៗទៀតផង។

ម.ស.ម.ក កំពុងស្វែងរកបេក្ខជនដែលមានចំណាប់អារម្មណ៍ក្នុងការដាក់ពាក្យដើម្បីទទួលបានការបណ្តុះបណ្តាលតាមរយៈគម្រោងនេះ។ ម.ស.ម.ក នឹងជ្រើសរើសសិក្ខាកាមចំនួនពី១៥ ទៅ ២០នាក់។ បេក្ខជនត្រូវមានការប្តេជ្ញាចិត្តក្នុងការចូលរួមក្នុងវគ្គបណ្តុះបណ្តាលទាំង ៥ វគ្គនេះ ក្នុងរយៈពេលប្រមាណជា ៦ ខែ ហើយត្រូវសរសេរអត្ថបទអំពីបញ្ហាសិទ្ធិមនុស្ស និងបញ្ហាសង្គមផ្សេងៗដែលពាក់ព័ន្ធ។ បេក្ខជនត្រូវតែជានិស្សិតស្ត្រីដែលរៀននៅ